**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតអនុគណៈកម្មការទទួលភារកិច្ចរៀបចំពិធីបុណ្យសព សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយស ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ០៦១៥/រកត/៦០៥ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈ-កម្មការរៀបចំពិធីបុណ្យសពសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយសក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា
- យោងសំណូមពរការងារ និងតម្រូវការចាំបាច់

**សម្រេច**

**មាត្រា ១.-**

បានបង្កើតអនុគណៈកម្មការជាជំនួយការទទួលបន្ទុកអនុវត្តការងាររបស់គណៈកម្មការរៀបចំពិធីបុណ្យសព សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈអធិបតីកិត្តិយសក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា មានសមាសភាពដូចខាងក្រោម៖

www.pheakdeylaw.com

ក-អនុគណៈកម្មការបដិសណ្ឋារកិច្ច និងពិធីការ

១-ឯកឧត្តម ឈិន កេតនា ប្រធាន

២-ឯកឧត្តម ណូ សម្បុក សមាជិក

៣-ឯកឧត្តម ជួង អេលីត សមាជិក

៤-ឯកឧត្តម ឈឹម សុន្ទរគុណា សមាជិក

៥-ឯកឧត្តម ព្រហ្ម វីរៈ សមាជិក

៦-ឯកឧត្តម ហ៊ឹម សុធារិទ្ធ សមាជិក

៧-ឯកឧត្តម ម៉ិន សេរី សមាជិក

៨-លោក ប្រាក់ ខុនហុង សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ច ៖

- ធ្វើបដិសណ្ឋារកិច្ចទទួលភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ដែលត្រូវចូលរួមក្នុងពិធីបុណ្យសព
- រៀបចំលិខិតស្នាមផ្សេងៗទាក់ទងជាមួយបណ្តាប្រទេស បណ្តាទូត និងអង្គការអន្តរជាតិនានា
- រៀបចំពិធីគោរពសពតាមកម្មវិធីដែលបានកំណត់
- អញ្ជើញភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ចូលរួមក្នុងពិធីបុណ្យសព និងពិធីបូជាសព
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

ខ-អនុគណៈកម្មការព័ត៌មាន និងផ្សព្វផ្សាយ

១-ឯកឧត្តម ខៀវ កាញារីទ្ធ ប្រធាន

២-ឯកឧត្តម ម៉ៅ អាយុទ្ធ សមាជិក

៣-ឯកឧត្តម ស្វាយ ស៊ីថា សមាជិក

៤-ឯកឧត្តម គីម គុណនាវឌ្ឍន៍ សមាជិក

៥-ឯកឧត្តម និត សុធា សមាជិក

៦-លោក ឡុង ឌីម៉ង់ សមាជិក

អនុគណៈកម្មការនេះមានភារកិច្ច ៖

- ធ្វើការផ្សាយព័ត៌មាន រូបភាព តាមវិទ្យុ ទូរទស្សន៍ជាតិ និងប្រព័ន្ធផ្សព្វផ្សាយនានាអំពីពិធីបុណ្យសព
- វិឃោសកថា និងឯកសារពាក់ព័ន្ធពិធីបុណ្យ
- រថយន្តមីក្រូ ឧបករណ៍សនស័ព្ទសម្រាប់ពិធីតាមតម្រូវការ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

គ-អនុគណៈកម្មការស្ថាបនាមេរុ រថយន្តបុស្បុក ក្បួនដង្ហែ និងពិធីសាសនា

១- សម្តេចចៅហ្វាវាំង គង់ សំអុល ប្រធាន

២- ឯកឧត្តម គុយ សុផល សមាជិក

៣- ឯកឧត្តម មិន ឃិន សមាជិក

៤- ឯកឧត្តម ឃឹម សារិទ្ធ សមាជិក

៥- ឯកឧត្តម ង៉ា សុជាតិវឌ្ឍ សមាជិក

៦- ឯកឧត្តម ឥត សារ៉ាត់ សមាជិក

៧- អ្នកឧកញ៉ាភក្តីព្រះសម្តេច ហេង គឹមគុណ សមាជិក

៨- ឯកឧត្តម យី ធន់ សមាជិក

៩- ឯកឧត្តម កែវ រតនៈ សមាជិក

១០- ឯកឧត្តម ស៊ឹម ស៊ីថា សមាជិក

១១-លោកជំទាវ ម៉ក់ ចន្ថាស៊ីថា សមាជិកា

អនុគណៈកម្មការនេះ មានភារកិច្ចៈ

- រៀបចំតម្លើងមេរុនៅទីតាំងដែលបានកំណត់ឲ្យបានទាន់ពេលវេលា ដោយត្រូវរៀបចំឲ្យបានស្របទៅនឹងប្រពៃណី រក្សារចនាបថខ្មែរ
- រៀបចំរថយន្តបុស្បុកសម្រាប់ដង្ហែ តាមចំនួនកំណត់សម្រាប់បម្រើពិធីដង្ហែសព
- រៀបចំពន្លា វេទិកា និងរោងមហាជន តុបតែងលម្អតាមតម្រូវការចាំបាច់
- ធ្វើកម្មវិធីលម្អិត សម្រាប់បម្រើការរៀបចំបុណ្យសព ពិធីដង្ហែសព និងពិធីបូជាសព
- ទំនាក់ទំនងក្នុងការនិមន្តព្រះសង្ឃ ចូលរួមទទួលភត្ត បង្សុកូល ចម្រើនព្រះបរិត្ត ទេសនា សូត្រព្រះធម៌
- ត្រៀមលក្ខណៈរៀបចំទេយ្យទាន សម្ភារៈ បរិក្ខារ សម្រាប់បម្រើកិច្ចការសាសនា តាមតម្រូវការ
- រៀបចំក្បួនដង្ហែសព ប្លង់ដង្ហែតាមមហាវិថីនានាឆ្លងកាត់ រូបភាពចាត់តាំងក្បួន តាមប្រពៃណី
- ផ្តល់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានស្តេរភាពបម្រើឲ្យពិធី
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

ឃ-<u>អនុគណៈកម្មការការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ និងសង្គ្រោះបន្ទាន់</u>

១- ឯកឧត្តម នេត សាវឿន ប្រធាន

២-ឯកឧត្តម យូ ស៊ុនឡុង សមាជិក

៣- ឯកឧត្តម តែ គុយស៊ាង សមាជិក

៤- ឯកឧត្តម សៅ សុខា សមាជិក

៥-ឯកឧត្តម ហេង រតនា សមាជិក

៦-ឯកឧត្តម ឃួង ស្រេង សមាជិក

៧-ឯកឧត្តម ឌុច ណារ៉ុង សមាជិក

៨-ឯកឧត្តម **ជូន សុវណ្ណ** សមាជិក

៩-ឯកឧត្តម **រ័ត្ន ស្រ៊ាង** សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ច៖

- រក្សាការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ សុខមាលភាព ឲ្យបាននាសុវត្ថិភាពក្នុងពេលប្រារព្ធពិធីបុណ្យសព រហូតដល់ថ្ងៃបញ្ចប់ពិធីបូជាសព
- ត្រៀមលក្ខណៈចាត់តាំងគ្រូពេទ្យ ថ្នាំពេទ្យ និងរថយន្តសង្គ្រោះសម្រាប់សង្គ្រោះបន្ទាន់ អ្នកមកចូលរួមពិធីបុណ្យសពរាល់ថ្ងៃ ពិធីដង្ហែ តម្កល់ និងបូជាសព
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

ង-<u>អនុគណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុ និងជីវភាព</u>

១-ឯកឧត្តម **ជូ គីមឡេង** ប្រធាន

២-ឯកឧត្តម **ឈិន កេតនា** សមាជិក

៣-ឯកឧត្តម **ខូន ឈឹមឃេង** សមាជិក

៤-ឯកឧត្តម **ម៉ែន ឥទ្ធិ** សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ច ៖

- លើកគម្រោងសម្ភារ ថវិកា ដែលត្រូវចំណាយសម្រាប់បម្រើការរៀបចំពិធី ដើម្បីសុំយោបល់សម្រេចពីគណៈ-កម្មការរៀបចំពិធីបុណ្យសព
- ដោះស្រាយសម្ភារ ថវិការបម្រើការរៀបចំពិធីបុណ្យសព ចាប់ពីថ្ងៃទទួលមរណភាពរហូតដល់ថ្ងៃដង្ហែ និងពិធីបូជាសព
- គ្រប់គ្រង និងប្រើប្រាស់សម្ភារ ថវិកាឲ្យបានឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាក់ស្តែងនៃការរៀបចំពិធីបុណ្យសព
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំពីប្រធានគណៈកម្មការ។

**មាត្រា ២.-**

អនុគណៈកម្មការនីមួយៗមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជួយការងារតាមតម្រូវការចាំបាច់។

**មាត្រា ៣.-**

ការចំណាយលើការងារផ្សេងៗរបស់អនុគណៈកម្មការនីមួយៗ ត្រូវដាក់ឆ្លងអនុគណៈកម្មការហិរញ្ញវត្ថុ និងសម្តេចចៅហ្វាវាំង **គង់ សំអុល** អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការ ពិនិត្យ និងសម្រេច ដោយប្រើប្រាស់ក្រាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ។ ក្នុងករណីមិនអាចសម្រេចបាន ត្រូវស្នើសុំសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងជាអនុប្រធាននៃគណៈកម្មការ ពិនិត្យ និងសម្រេច។

www.pheakdeylaw.com

**មាត្រា ៤.-**

អនុគណៈកម្មការនីមួយៗត្រូវបូកសរុបរាយការណ៍ ការងាយស្រួល ការលំបាក សំណូមពរជូនសម្តេចចៅហ្វាវាំង អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការ ដើម្បីពិនិត្យ ដោះស្រាយ និងផ្តល់យោបល់ជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ពិនិត្យ សម្រេច។

**មាត្រា ៥.-**

សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដូចក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពខ្ពស់។

**មាត្រា ៦.-**

អនុក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com